# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្ដីការគណៈរដ្ឋមន្ត្រី
ឆ្នាំទី ១១ លេខ ៥

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

# សកម្មភាព ការងារ

ECOSOCC

ក ស វ



# Work Activities

ប្រចាំខែឧសភា ឆ្នាំ២០១៨



# មាតិកា


| ល.រ បរិយាយ | លេខទំព័រ |
|---|---|
| I- កិច្ចប្រជុំជំនាញបច្ចេកទេស | |
| - សេចក្តីព្រាងច្បាប់ស្តីពីការប្រកួតប្រជែង | ១-២ |
| II- សកម្មភាពការងាររបស់ក្រុមវាយតម្លៃលើផលប៉ះពាល់លិខិតបទដ្ឋានគតិយុត្ត( ក្រុម RIA ) | |
| - វគ្គបណ្តុះបណ្តាលអំពីវិធីសាស្ត្រវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត នៅក្រសួងរ៉ែ និងថាមពល ចាប់ពីថ្ងៃទី១៧ ដល់ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៨ | ៣-៥ |
| III- កិច្ចប្រជុំស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជាប្រចាំខែមេសា ឆ្នាំ២០១៨ | ៥-១៣ |
| IV- សកម្មភាពដទៃទៀតរបស់ ឯកឧត្តម ទេសរដ្ឋមន្ត្រី **យឹម ណុលឡា** ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែឧសភា ឆ្នាំ២០១៨ | ១៤-១៥ |

# សេចក្តីព្រាងច្បាប់ស្តីពី ការប្រកួតប្រជែង

កាលពីថ្ងៃព្រហស្បតិ៍១២កើត ខែពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦១ និងថ្ងៃអង្គារ៩រោច ខែពិសាខ និងថ្ងៃពុធ៩កើត ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃ២៦ ខែមេសា និងថ្ងៃទី០៨ ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៨ នៅទីស្តីការគណៈរដ្ឋមន្ត្រីមានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **អ៊ុច ថោងសេង** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និង ឯកឧត្តម **ជីវ សុខហាក់** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើ**សេចក្តីព្រាងច្បាប់ស្តីពី ការប្រកួតប្រជែង** ដោយមានការអញ្ជើញចូលរួមពី សមាជិកនិងមន្ត្រីនៃក.ស.វ. សមាជិកនិងមន្ត្រីនៃប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល មន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងក្រសួងពាណិជ្ជកម្ម។



សេចក្តីព្រាងច្បាប់ស្តីពីការប្រកួតប្រជែង ជាផ្នែកមួយដ៏សំខាន់នៃប្រព័ន្ធច្បាប់នៅលើពិភពលោក ដែលជំរុញដំណើរការទីផ្សារប្រកបដោយប្រសិទ្ធភាព និងជំរុញសេដ្ឋកិច្ចជាតិឲ្យរីកចម្រើន។ សព្វថ្ងៃប្រទេសចំនួន១៣០ លើសកលលោក ដែលក្នុងនោះមានប្រទេស៩ នៃបណ្តាប្រទេសអាស៊ានទាំង១០ បាននឹងកំពុងអនុវត្តច្បាប់ប្រកួតប្រជែង។ ច្បាប់នេះដើរស្របគ្នាជាមួយច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់។

សេចក្តីព្រាងច្បាប់នេះមានសារប្រយោជន៍ដូចខាងក្រោម ៖

- ការពារ និងលើកទឹកចិត្តដល់ពាណិជ្ជករឲ្យធ្វើការប្រកួតប្រជែងដោយស្មើភាព ដែលធ្វើឲ្យមានប្រសិទ្ធភាពសេដ្ឋកិច្ច និងទាក់ទាញការវិនិយោគ ក៏ដូចជាការបង្កើតធុរកិច្ចថ្មីៗឲ្យបានច្រើន។
- ការពារសេដ្ឋកិច្ចជាតិពីផលប៉ះពាល់ដែលបណ្តាមកពីសកម្មភាព កិច្ចព្រមព្រៀងមិនស្របច្បាប់ ការរំលោភបំពានដោយជំហរឧត្តមភាពទីផ្សារ និងការរួមបញ្ចូលគ្នានៃធុរកិច្ចទាំងឡាយណាដែលមាន ឬអាចមានអានុភាពរារាំង រិតត្បិត ឬបង្ខូចដល់ការប្រកួតប្រជែង។
- ជួយអ្នកប្រើប្រាស់ឲ្យទទួលបានទំនិញនិងសេវាកម្មក្នុងតម្លៃទាប មានគុណភាពខ្ពស់ មានភាពសម្បូរបែប និងមានជម្រើសច្រើន។

លក្ខណៈពិសេសរបស់សេចក្តីព្រាងច្បាប់ស្តីពីការប្រកួតប្រជែង ៖

- សេចក្តីព្រាងច្បាប់នេះមានវិសាលភាពអនុវត្តចំពោះបុគ្គលធ្វើសកម្មភាពធុរកិច្ច ឬសកម្មភាពគាំទ្រដល់ធុរកិច្ច ដែលរារាំង រិតត្បិត ឬបង្ខូចដល់ការប្រកួតប្រជែងគួរឲ្យកត់សម្គាល់ក្នុងទីផ្សារនៃព្រះរាជាណាចក្រកម្ពុជា ទោះបីសកម្មភាពនោះមានប្រភពនៅក្នុង ឬក្រៅប្រទេសក៏ដោយ។

- ច្បាប់នេះអនុវត្តចំពោះរាល់បុគ្គលទាំងឡាយណាដែលធ្វើសកម្មភាពគាំទ្រដល់ធុរកិច្ច ទោះបីក្នុងគោលបំណងស្វែងរកប្រាក់ចំណេញ មិនស្វែងរកប្រាក់ចំណេញ ឬក្នុងគោលបំណងសប្បុរសធម៌ និងទោះបីបុគ្គលទាំងនោះមានទម្រង់ជាកម្មសិទ្ធិឯកជន ឬជាកម្មសិទ្ធិរដ្ឋក៏ដោយ។

ប្រវត្តិនៃការធ្វើសេចក្ដីព្រាងច្បាប់ស្ដីពីការប្រកួតប្រជែង ៖

សេចក្ដីព្រាងច្បាប់នេះបានតាក់តែងឡើង នៅក្រោមលក្ខខណ្ឌតម្រូវរបស់អង្គការពាណិជ្ជកម្មពិភពលោក(WTO) ជាមួយក្រសួងពាណិជ្ជកម្ម នៅពេលកម្ពុជាសុំចូលជាសមាជិកអង្គការនេះនៅឆ្នាំ២០០៤។ នៅឆ្នាំ២០០៦ ដល់ឆ្នាំ២០០៨ ក្រសួងពាណិជ្ជកម្មបានទទួលជំនួយពីជំនាញការ UNCTAD ហើយរៀបចំសេចក្ដីព្រាងច្បាប់ស្ដីពីការប្រកួតប្រជែងនេះឡើង។ ពីឆ្នាំ២០១២ ដល់ឆ្នាំ២០១៣ ADB បានផ្ដល់អ្នកជំនាញការ មកជួយពិនិត្យសេចក្ដីព្រាងច្បាប់នេះឡើងវិញ។



ចាប់ពីឆ្នាំ២០១៥ ដល់ឆ្នាំ២០១៧ កន្លងមកនេះ គណៈកម្មាធិការប្រកួតប្រជែង និងអ្នកប្រើប្រាស់អូស្ត្រាលី(ACCC) បានផ្ដល់ជំនាញការពីរនាក់ ជួយពិនិត្យបន្ថែមភាពខ្វះចន្លោះ និងប្រជុំពិភាក្សាជាមួយក្រុមការងារសេចក្ដីព្រាងច្បាប់ប្រកួតប្រជែងនៃក្រសួងពាណិជ្ជកម្ម និងជាមួយតំណាងក្រុមប្រឹក្សាអ្នកច្បាប់ នៃទីស្ដីការគណៈរដ្ឋមន្ត្រី ជាច្រើនលើក ច្រើនសារ រហូតដល់បានបញ្ចប់សេចក្ដីព្រាងច្បាប់នេះទាំងស្រុង[១]។

អង្គប្រជុំបានពិនិត្យពិភាក្សាលើសេចក្ដីព្រាងអនុក្រឹត្យនេះ ហើយបានសម្រេចកែសម្រួលទម្រង់ខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគផ្សេងទៀត ដើម្បីធ្វើឲ្យសេចក្ដីព្រាងនេះកាន់តែល្អ៕

(១) អត្ថបទនេះដកស្រង់ពីសេចក្ដីព្រាងសេចក្ដីថ្លែងហេតុរបស់សេចក្ដីព្រាងច្បាប់ស្ដីពីការប្រកួតប្រជែង។

# វគ្គបណ្តុះបណ្តាលអំពី វិធីសាស្ត្រវាយតម្លៃលើផលប៉ះពាល់ នៃលិខិតបទដ្ឋានគតិយុត្ត

## នៅក្រសួងរ៉ែនិងថាមពល

### ចាប់ពីថ្ងៃទី១៧ ដល់ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៨

ក្រុមប្រតិបត្តិលិខិតបទដ្ឋានគតិយុត្តរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី បានបើកវគ្គបណ្តុះបណ្តាលស្តីពីវិធីសាស្ត្រវាយតម្លៃលើផលប៉ះពាល់ នៃលិខិតបទដ្ឋានគតិយុត្ត (Regulatory Impact Assessment Methodology) ជូនដល់មន្ត្រីក្រសួងរ៉ែ និងថាមពល ប្រមាណ ៧០នាក់។

កម្មវិធីបើកវគ្គបណ្តុះបណ្តាលនេះក្រោមអធិបតីភាពឯកឧត្តម **យឹម ណុលសន** អនុប្រធាន ECOSOCC និងជាប្រធានក្រុមប្រតិបត្តិលិខិតបទដ្ឋានគតិយុត្ត និងឯកឧត្តម **ស៊ុយ ឌីម៉ង់** អគ្គនាយក នៃអគ្គនាយកដ្ឋានកិច្ចការទូទៅ ក្រសួងរ៉ែ និងថាមពល ហើយវាគ្មិនរួមមាន ឯកឧត្តម **ប៉ិច សុខា** អគ្គលេខាធិការរង ECOSOCC និងជាអនុប្រធានអចិន្ត្រៃយ៍ក្រុមប្រតិបត្តិលិខិតបទដ្ឋានគតិយុត្ត និង ឯកឧត្តម





**អេង រត្នមុន្នី** អគ្គលេខាធិការរង ECOSOCC និងជាប្រធានផ្នែកបណ្តុះបណ្តាលនៃក្រុមប្រតិបត្តិលិខិតបទដ្ឋានគតិយុត្ត។

អតីតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលបានចាប់ផ្តើមអនុវត្តវិធីសាស្ត្រ RIA សាកល្បងកាលពីឆ្នាំ ២០០៨ ដោយទទួលបានលទ្ធផលគួរជាទីពេញចិត្ត។ ផ្តើមចេញពីលទ្ធផលនេះ ADB ដែលជាអ្នកផ្តល់មូលនិធិគាំទ្រដល់ការអនុវត្ត RIA បានពង្រីកវិសាលភាពនៃការអនុវត្ត RIA ដោយអញ្ជើញក្រសួង ស្ថាប័ន ចូលរួមអនុវត្តឲ្យបានច្រើន ហើយបានស្នើសុំECOSOCC ដើរតួនាទី ជាស្ថាប័នបណ្តុះបណ្តាល។

RIA បានក្លាយជាកម្មវិធីមួយដោយបានអនុវត្តសាកល្បងតាំងពីឆ្នាំ២០១១ ដល់ឆ្នាំ២០១៦ ដែល ECOSOCC ជាអង្គភាពប្រតិបត្តិកម្មវិធី និងមានការចូលរួមអនុវត្តកម្មវិធីដោយក្រសួងចំនួន១៨ ក្រោមហិរញ្ញប្បទានឥតសំណង និងជំនួយបច្ចេកទេសរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ADB។ ដោយការអនុវត្តទទួលបាន



លទ្ធផលល្អ រាជរដ្ឋាភិបាលបានចេញសេចក្ដីសម្រេចលេខ ១៣២ សសរ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៦ ស្ដីពីការបង្កើតក្រុមការងារវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត។

ដើម្បីពង្រឹងសមត្ថភាពមន្ត្រី RIA ក្រុមការងារ RIA នៃក្រសួងរ៉ែ និងថាមពល បានស្នើសុំក្រុមប្រតិបត្តិលិខិតបទដ្ឋានគតិយុត្ត ដែលជាស្ថាប័នបង្គោលក្នុងការបណ្ដុះបណ្ដាល និងផ្សព្វផ្សាយវិធីសាស្រ្ត RIA ផ្ដល់ការបណ្ដុះបណ្ដាលអំពី RIA ដល់មន្ត្រីនៃក្រសួងរ៉ែ និងថាមពល។

ការអនុវត្ត RIA ដោយពេញលេញជួយធ្វើឲ្យលិខិតបទដ្ឋានគតិយុត្តមានគុណភាពខ្ពស់ ដែលនាំឲ្យមានអភិបាលកិច្ចល្អ ជំរុញកំណើនសេដ្ឋកិច្ច បង្កើនតម្លាភាពនិងគណនេយ្យភាព កាត់បន្ថយការិយាធិបតេយ្យ កាត់បន្ថយការជាន់សមត្ថកិច្ចគ្នា កាត់បន្ថយបន្ទុកចំណាយរដ្ឋបាលលើការអនុវត្ត និងកាត់បន្ថយបន្ទុកចំណាយប្រតិបត្តិការរបស់ធុរកិច្ចជាដើម ហើយពិសេសទៅទៀត គឺពង្រឹងជំនឿទុកចិត្តពីសាធារណជន និងធុរជនលើលិខិបទដ្ឋានគតិយុត្ត។ RIA ទាមទារឲ្យក្រសួងអនុវត្តគោលការណ៍ប្រតិបត្តិល្អក្នុងនីតិវិធីតាក់តែងលិខិតបទដ្ឋានគតិយុត្ត និងធ្វើការវាយតម្លៃឲ្យបានហ្មត់ចត់លើផលប៉ះពាល់ ដែលអាចកើតមានឡើងពីបទប្បញ្ញត្តិនានា នៅអំឡុងពេលរៀបចំសេចក្ដីព្រាង ដើម្បីជៀសវាង ឬកាត់បន្ថយជាអតិបរមានូវផលប៉ះពាល់ជាអវិជ្ជមានដល់ធុរកិច្ច និងសង្គមទាំងមូល៕

# III- កិច្ចប្រជុំស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា ប្រចាំខែមេសា ឆ្នាំ២០១៨



របាយការណ៍ស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ **ប្រចាំខែមេសា ឆ្នាំ២០១៨** នេះ ជាលទ្ធផលនៃកិច្ចប្រជុំទូលាយក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) នៅថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៨ ក្រោមអធិបតីភាព លោកជំទាវ **តាល់ ណៃអុីម** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដោយមានការអញ្ជើញចូលរួមពី អនុប្រធាន សមាជិក សមាជិកា អគ្គលេខាធិការ អគ្គលេខាធិការរង នៃ ក.ស.វ. និងតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ។

## ១) ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងអត្រាប្តូរប្រាក់

➡ នាខែមេសា ឆ្នាំ២០១៨ នៅមិនទាន់បានទទួលតួលេខ ស្តីពីសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅឡើយ ពីវិទ្យាស្ថានស្ថិតិ។ ក.ស.វ សូមដាក់របាយការណ៍វិភាគប្រចាំខែមីនាម្តងទៀត។

➡ នាខែមីនា ឆ្នាំ២០១៨សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់កើនឡើង០,០៤% ធៀបនឹងខែមុន និងកើនឡើង២,៣% ធៀបនឹងខែដូចគ្នាឆ្នាំមុន (រយៈពេល១២ខែ)។

តារាង១.១. បម្រែបម្រួលថ្លៃធៀបនឹងខែដូចគ្នាឆ្នាំមុនសម្រាប់ក្រុមទំនិញនិងមុខទំនិញមួយចំនួន

| *ក្រុមទំនិញ:* | | *មុខទំនិញ:* | |
|---|---|---|---|
| ភោជនីយដ្ឋាន: | +៧,៥% | ឧស្ម័ន | +៦,៩% |
| ទំនិញ និងសេវាកម្មផ្សេងៗ | +៣,៦% | ប្រេងសាំង: | +៥,៣% |
| ការដឹកជញ្ជូន: | +២,៥% | ប្រេងម៉ាស៊ូត: | +៤,២% |
| ម្ហូបអាហារ: | +២,២% | ត្រីស្រស់: | +៤,៨% |
| ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ទនៈផ្សេងទៀត | +១,៣% | សាច់គោ: | +២,៨% |
| សំលៀកបំពាក់ និងស្បែកជើង: | +១,៣% | សាច់ជ្រូក: | +០,៧% |
| សុខាភិបាល: | +១,២% | សាច់មាន់: | +០,៦% |
| គ្រឿងសង្ហារឹមនិងសម្ភារៈប្រើប្រាស់: | +០,៥% | | |

តារាង១.២. បម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ២០១៦–២០១៨

| ឆ្នាំ | ធៀបនឹងខែ | មករា | កុម្ភៈ | មីនា | មេសា P | ឧសភា P | មិថុនា P | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | ប្រចាំឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០១៨ | ដូចគ្នាឆ្នាំមុន | ២,០% | ២,៣% | ២,៣% | ២,២% | ២,៦% | ២,៩% | | | | | | | |
| | មុន | ០,១% | ០,៤% | ០,០៤% | ០,៣% | ០,២% | ០,៤% | | | | | | | |
| ២០១៧ | ដូចគ្នាឆ្នាំមុន | ៤,៤% | ៤,០% | ៤,២% | ៣,២% | ២,៥% | ២,៣% | ២,៣% | ២,៦% | ២,៧% | ២,១% | ២,៣% | ២,២% | ២,៩% |
| | មុន | ០,៣% | ០,១% | ០,០% | ០,៤% | -០,២% | ០,១% | ០,៣% | ០,៤% | ០,៣% | -០,២% | ០,២% | ០,៤% | |
| ២០១៦ | ដូចគ្នាឆ្នាំមុន | ៣% | ២,៣% | ២,០% | ២,៨% | ៣,១% | ៣,៣% | ៣,០% | ២,៩% | ៣,០% | ៣,៤% | ៣,៦% | ៣,៩% | ៣% |
| | មុន | -០,២% | ០,៤% | -០,២% | ១,៤% | ០,៥% | ០,២% | ០,៣% | ០,២% | ០,៣% | ០,៤% | ០ | ០,៤% | |

P: តួលេខខែមេសា ឧសភា និងមិថុនា ឆ្នាំ២០១៨ ជាតួលេខព្យាករ (តាមវិធីសាស្រ្ត DECOMPOSITION)

* ការវិភាគជាសំណេរដកស្រង់ចេញពីទិន្នន័យសំខាន់ៗប៉ុណ្ណោះ មិនគ្រប់ដណ្តប់តួលេខទាំងអស់ទេ (មើលតារាងភ្ជាប់មកជាមួយ)។
* ដើម្បីមានសង្គតិភាពក្នុងការប្រើប្រាស់លេខខ្មែរ និងអន្តរជាតិ សញ្ញាក្បៀសនៅក្នុងអត្ថបទ តាងឲ្យទសភាគ។ ប៉ុន្តែក្នុងតារាងលេខ (Excel) សញ្ញាក្បៀសតាងឲ្យខ្ទង់ពាន់ ឯសញ្ញាចុចជាទសភាគវិញ។

ក្រាហ្វ ១.១. ចលនានិងបម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់តារាង




១.៣. អត្រាប្តូរប្រាក់

| *ប្រភេទ* | មេសា ២០១៨ | មីនា ២០១៨ | មេសា ២០១៧ | *ប្រភេទ* | មេសា ២០១៨ | មីនា ២០១៨ | មេសា ២០១៧ |
|---|---|---|---|---|---|---|---|
| **៛/ដុល្លារ** | ៤០៣២៛/១$ | ៤០០០៛/១$ | ៤០៣៤៛/១$ | **បាត/ដុល្លារ** | ៣១,៥០បាត/១$ | ៣១,២៤បាត/១$ | ៣៤,៥៩បាត/១$ |
| **៛/បាត** | ១២៨៛/១បាត | ១២៨៛/១បាត | ១១៧៛/១បាត | **ដុង/ដុល្លារ** | ២២៧២០ដុង/១$ | ២២៨០៥ដុង/១$ | ២២៧៣០ដុង/១$ |
| **៛/ដុង** | ០,១៧៧៛/១ដុង | ០,១៧៥៛/១ដុង | ០,១៧៧៛/១ដុង | | | | |

## ២) ស្ថានភាពថវិកាជាតិ

➡យោងតាមស្ថិតិរបស់ធនាគារជាតិ អគ្គនាយកដ្ឋានគយនិងរដ្ឋាករ និងអគ្គនាយកដ្ឋានពន្ធដារក្នុងខែមេសា ឆ្នាំ ២០១៨ ថវិកាជាតិមានស្ថានភាពដូចខាងក្រោម:

**២.១. ចំណូលថវិកាជាតិ** : អនុវត្តបាន១៨៥៣,១ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ ៤៦៣,៣ លានដុល្លារ (*មធ្យមប្រចាំខែ ៩៩,៨% នៃផែនការ*) ក្នុងនោះចំណូលចរន្តចំនួន១៨០១,៤ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ ៤៥០,៣ លានដុល្លារ ( *មធ្យមប្រចាំខែ ១០១% នៃផែនការ*) និងចំណូលមូលធនចំនួន៥១,៧ប៊ីលានរៀល (តាមតួលេខ ធនាគារជាតិ)។

➢បើធៀបនឹងខែមុន ចំណូលថវិកាជាតិកើនឡើង២២,៨% និងកើនឡើង១២,១%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

ក្រាហ្វ ២.១. ចំណូលថវិកាជាតិ ឆ្នាំ ២០១៦-២០១៨ (ប៊ីលានរៀល)




➢នៅក្នុងចំណូលចរន្ត:

✓ចំណូលសារពើពន្ធមានចំនួន ១៦០៧,៥ប៊ីលានរៀលកើនឡើង១៤,៦% ធៀបនឹងខែមុននិង កើនឡើង១៧% ធៀបនឹងខែដូចគ្នាឆ្នាំមុន(តាមតួលេខ ធនាគារជាតិ)។

✓ចំណូលមិនមែនសារពើពន្ធ មានចំនួន១៩៣,៩ប៊ីលានរៀល កើនឡើង១០៨,២% ធៀបនឹងខែមុន និងកើនឡើង ៥៥,៥% ធៀបនឹងខែដូចគ្នាឆ្នាំមុន(តាមតួលេខ ធនាគារជាតិ)។

**តារាង២.១. មុខចំណូលមួយចំនួនក្នុងចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ**

| **ចំណូលសារពើពន្ធ**<br>(ក្នុងវង់ក្រចក:បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន) | | **ចំណូលមិនមែនសារពើពន្ធ**<br>(តាមតួលេខ រតនាគារជាតិ)<br>(ក្នុងវង់ក្រចក:បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន) | |
|---|---|---|---|
| ➢ ពន្ធ និងអាករគយ: -១១,២% | (+១៨%) | ➢កាស៊ីណូ : +១៧,៣% | (+២៨,៨%) |
| (អគ្គនាយកដ្ឋានគយ និងរដ្ឋាករ) | | ➢អាជ្ញាបណ្ណក្នុងស្រុក : កើនឡើងគំហ៊ុក | (+២៩០,២%) |
| ➢ ចំណូលពន្ធដារ: +៦,៤% | (+៩,៦%) | ➢ នេសាទ:-៣៨% | (-១០,២%) |
| (អគ្គនាយកដ្ឋានពន្ធដារ) | | ➢សម្បទានរ៉ែ: +១៥៩,២% | (+៥៦,១%) |
| | | ➢ អាកាសចរណ៍ស៊ីវិល: -៤,១% | (-១៨,៧%) |

**២.២. ចំណាយថវិកាជាតិ** :អនុវត្តបាន ១១១០,៥ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ ២៧៧,៦៣ លានដុល្លារ (*មធ្យមប្រចាំខែ ៦៧% នៃផែនការ*) ក្នុងនោះ ចំណាយចរន្តចំនួន ៩៤៣,២ប៊ីលានរៀល (*មធ្យមប្រចាំខែ ៧៣% នៃផែនការ*) និងចំណាយមូលធនមានចំនួន១៦៧,៣ប៊ីលានរៀល(តាមតួលេខ រតនាគារជាតិ)។

➢ចំណាយថវិកាជាតិថយចុះ១២,៦% ធៀបនឹងខែមុនប៉ុន្តែកើនឡើង៣៤,២%ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះចំណាយចរន្តថយចុះ៩,១% ធៀបនឹងខែមុនប៉ុន្តែកើនឡើង៣៥,៤%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

**២.៣. សមតុល្យថវិកាជាតិ** : ថវិកាជាតិនាខែនេះមានអតិរេកចំនួន ៧៤២,៦ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ ១៨៥,៦៥ លានដុល្លារ (តួលេខរតនាគារជាតិ)។

ក្រាហ្វ២.២. ចំណាយថវិកាជាតិ ឆ្នាំ ២០១៦–២០១៨

(ប៊ីលានរៀល)




## ៣) ស្ថានភាពរូបិយវត្ថុនិងអត្រាការប្រាក់

➡ស្ថានភាពរូបិយវត្ថុ ក្នុងខែមេសា ឆ្នាំ២០១៨មានលក្ខណៈដូចខាងក្រោម:

➢រូបិយវត្ថុ$M_2$ មានចំនួន៧៦៣៥៦ប៊ីលានរៀល កើនឡើង១,៦%ធៀបនឹងខែមុន និងកើនឡើង២៣,៧% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ **ការកើនឡើង$M_2$** ក្នុងខែនេះ ជារួមបណ្តាលមកពីការកើនឡើងនៃរូបិយវត្ថុក្រៅធនាគារ២,៧% និងប្រាក់បញ្ញើជារូបិយបណ្ណ១,៩%។

ក្រាហ្វ៣.១. សមាសធាតុរូបិយវត្ថុខែមេសាឆ្នាំ២០១៨




➢ក្នុងខែនេះ ប្រាក់រៀលសរុបនៅក្នុងនិងក្រៅធនាគារមានចំនួន១៥,៣% និងប្រាក់បញ្ញើជារូបិយបណ្ណមានចំនួន ៨៤,៧% នៃរូបិយវត្ថុ$M_2$។

តារាង៣.១. សមាមាត្រចំនួនប្រាក់រៀល នៅក្នុងរូបិយវត្ថុ $M_2$ ឆ្នាំ២០១៨

| ប្រាក់រៀលសរុបនៅក្នុងនិងក្រៅធនាគារ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ១៦,៨% | ១៦,៧% | ១៥,៥% | ១៥,៣% | | | | | | | | |
| ប្រាក់រៀលក្រៅធនាគារ | ១១,៦% | ១១,៥% | ១១,៣% | ១១,៤% | | | | | | | | |

ក្រាហ្វ៣.២.បម្រែបម្រួលសមាសធាតុរូបិយវត្ថុខែមេសា២០១៨: ក្នុងវង់ក្រចកជាបម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន




➢**ទុនបម្រុងជារូបិយបណ្ណបរទេសសុទ្ធ** មានចំនួន៨៨៧៧លានដុល្លារ កើនឡើង០,៦%ធៀបនឹងខែមុន និងកើនឡើង២០,៣% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢ ***ប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជនៅធនាគារជាតិ*** ក្នុងខែនេះមានចំនួន ២៧៤៨៨ ប៊ីលានរៀលកើនឡើង១% ធៀបនឹងខែមុន និងកើនឡើង២៩%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង៣.២.ការផ្តល់ឥណទាននិងអត្រាការប្រាក់ប្រចាំឆ្នាំ

| *ផ្តល់ដោយ* | *មេសា២០១៨* | *មីនា២០១៨* | *មេសា២០១៧* |
|---|---|---|---|
| ឥណទានផ្តល់ដោយធនាគារពាណិជ្ជ(ប៊ីលានរៀល) | ៧១៤៦៩ | ៧០៣០០ | ៥៩៦៦៤ |
| ក្នុងនោះ ជារៀល | | ១៨៧១ | ១០៣១ |
| ឥណទានផ្តល់ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ(ប៊ីលានរៀល) | | ១៨៤៧៥ | ១៣៨៣៦ |
| អត្រាការប្រាក់បញ្ញើជារៀលនៅធនាគារពាណិជ្ជ | ៥,៩៧% | ៦,០៤% | ៦,០២% |
| អត្រាការប្រាក់កម្ចីជារៀលនៅធនាគារពាណិជ្ជ | ១១,៥៩% | ១២,០៣% | ១៤,៨៤% |
| អត្រាការប្រាក់បញ្ញើជាដុល្លារនៅធនាគារពាណិជ្ជ | ៤,៤១% | ៤,៤២% | ៤,៤០% |
| អត្រាការប្រាក់កម្ចីជាដុល្លារនៅធនាគារពាណិជ្ជ | ១១,២៧% | ១១,៤៥% | ១១,៦៨% |
| អត្រាការប្រាក់កម្ចីជារៀលនៅហត្ថកសិករ | ១៨% | ១៨% | ១៥% |
| អត្រាការប្រាក់កម្ចីជារៀលនៅអម្រឹត | ១៨% | ១៨% | ២៧% |
| អត្រាការប្រាក់កម្ចីជារៀលនៅប្រាសាក់ | ១៧,៩% | ១៦,១% | ២២,៨% |

## ៤)ស្ថានភាព កសិកម្ម ឧស្សាហកម្ម សេវាកម្ម និងវប្បធម៌

➡ក្នុងខែមេសា ឆ្នាំ២០១៨ ស្ថានភាពផលិតកម្មមានលក្ខណៈដូចខាងក្រោម:

➢**កសិកម្ម**:

✓នេសាទសម្រេចបាន៥១ពាន់តោនកើនឡើង៥% ធៀបនឹងខែមុននិង កើនឡើង៧,២%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢ រ៉ែ និងថាមពល:

✓ អគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជាមានចំនួន៧៧៥,១៦GWHមានការកើនឡើង៥,១%ធៀបនឹងខែមុន និងកើនឡើង២០%ធៀបនឹងខែដូចគ្នាឆ្នាំមុន ក្នុងនោះផ្គត់ផ្គង់ដោយវារីអគ្គិសនីមានចំនួន២០៧,៣៥GWHមានការ កើនឡើង២៧% ធៀបនឹងខែមុន ប៉ុន្តែមានការថយចុះ១៤% ធៀបនឹងខែដូចគ្នាឆ្នាំមុន អគ្គីសនីផ្គត់ផ្គង់ដោយធ្យូងថ្មមានចំនួន៣៨១,៧៨GWHមានការកើនឡើង១០,៩%ធៀបនឹងខែមុននិងមានការកើនឡើង២៤% ធៀបនឹងខែដូចគ្នាឆ្នាំ មុន អគ្គិសនីដែលនាំចូលពីប្រទេសជិតខាងដោយ EDC មានចំនួន១៤៩,២៦GWHមានការ ថយចុះ១៧% ធៀបនឹងខែមុន ប៉ុន្តែមានការកើនឡើង៦៩%ធៀបនឹងខែដូចគ្នាឆ្នាំមុន និងអគ្គិសនីផ្គត់ផ្គង់ដោយប្រភពផ្សេងទៀតមានចំនួន៣៦,៧៧GWHមានការថយចុះ២៥,៦% ធៀបនឹងខែមុន ប៉ុន្តែមានការកើនឡើង៣២៦% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢ ឧស្សាហកម្ម:

✓ផលិតកម្មវាយនភណ្ឌនិងស្បែកជើងមានចំនួន ៦៦៥,៣លានដុល្លា កើនឡើង៦% ធៀបនឹងខែមុននិង កើនឡើង៣៥,៩%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង៤.១. ការចុះបញ្ជីរោងចក្រ និងឧស្សាហកម្មធុនតូច និងសិប្បកម្ម នៅក្រសួងឧស្សាហកម្ម

| *ប្រភេទ* | *ចំនួន — មេសា២០១៨* | *ចំនួន— មីនា២០១៨* | *ចំនួន— មេសា២០១៧* |
|---|---|---|---|
| ▪រោងចក្រថ្មីដែលបានចុះបញ្ជី | ១៣ | ១១ | ១៦ |
| ▪ ចំនួនរោងចក្រសរុបដែលមានក្នុងបញ្ជី | ១៥៦៩ | ១៥៥៦ | ១៦០៧ |
| ▪ ឧស្សាហកម្មធុនតូច និងសិប្បកម្ម(បើកថ្មី) | ៩ | ១៦ | ២១ |
| ▪ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បន្ត) | ១៦ | ៣០ | ១៨ |

➢ **សំណង់** (ការអនុញ្ញាត):

✓សំណង់អនុញ្ញាតឲ្យសាងសង់មានចំនួន៣០០៥,៤ពាន់ម$^{2}$កើនឡើង៧៤៤%ធៀបនឹងខែមុន ប៉ុន្តែថយចុះ១៥%ធៀបនឹងខែដូចគ្នាឆ្នាំមុន។ បើគិតជាសាច់ប្រាក់ស្មើនឹង១១៣២,៤លានដុល្លារកើនឡើង៧០៥%ធៀបនឹងខែមុន ប៉ុន្តែថយចុះ៥៩%បើធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះប្រភេទសំណង់ចម្បងៗមាន:

តារាង៤.២. សំណង់អនុញ្ញាតតាមប្រភេទផ្សេងៗ

| *ប្រភេទ* | *ពាន់ម$^{2}$ — មេសា២០១៨* | *ពាន់ម$^{2}$ — មីនា២០១៨* | *ពាន់ម$^{2}$ — មេសា២០១៧* |
|---|---|---|---|
| ▪ លំនៅឋាន | ៩៤៨,០ | ១៦០,៨ | ១៣១៧,៣ |
| ▪ ឧស្សាហកម្ម | ៥,៩ | ៩៩,០ | ៣៣,៨ |
| ▪ពាណិជ្ជកម្ម | ៤៧,៦ | ៨៧,៥ | ២១៤១,២ |
| ▪ ទេសចរណ៍ | ១៨៨៥,៣ | ៧,៨ | ៣៨,៤ |
| ▪ផ្សេងៗ | ០,០ | ០,០ | ០,៧ |
| អនុញ្ញាតសរុប | ៣០០៥,៤ | ៣៥៦,៣ | ៣៥៣២,០ |

✓ដូច្នេះសំណង់អនុញ្ញាតដែលពេញនិយមនាខែនេះគឺទេសចរណ៍៦២,៧%និង លំនៅដ្ឋាន៣១,៥%នៃផ្ទៃក្រឡាសរុប។

## ➢ការងារ

តារាង៤.៣. ការស្វែងរកការងារនិងទទួលបានការងារ

| ប្រភេទ | នាក់– មេសា ២០១៨ | នាក់–មីនា ២០១៨ | នាក់–មេសា ២០១៧ |
|---|---|---|---|
| អ្នកចុះឈ្មោះស្វែងរកការងារ (ទីភ្នាក់ងារជាតិមុខរបរនិងការងារ) | ១៥២៨ | ១៧៣៧ | ១៣១០ |
| អ្នកទទួលបានការងារតាមរយៈក្រសួងការងារ និងក្រុមហ៊ុន | ១៧៨៧៦ | ១៤៧១២ | ១១៩៣៣ |
| អ្នកទទួលបានការងារក្នុងប្រទេស | ១៣២៨៦ | ៩៧៨៨ | ៨៧៣៧ |
| អ្នកទទួលបានការងារក្រៅប្រទេស | ៤៥៩០ | ៤៩២៤ | ៣១៩៦ |

## ➢វិនិយោគ

តារាង៤.៤.គម្រោងវិនិយោគអនុញ្ញាតដោយគ.វ.ក./ក.អ.ក. (ថ្មីនិងពង្រីក)

| ប្រភេទ | មេសា២០១៨ | មីនា២០១៨ | មេសា២០១៧ |
|---|---|---|---|
| អនុញ្ញាតសរុប (លានដុល្លារ) | ១៧៨,៣ | ៣៥៧,៧ | ៨៧,២ |
| វិស័យកសិកម្មនិងកសិឧស្សាហកម្ម | ០,០ | ១៦៩,៨ | ០,០ |
| វិស័យឧស្សាហកម្ម (ក្នុងវង់ក្រចកជាតួលេខនៃតំបន់សេដ្ឋកិច្ចពិសេស) | ៧៩,៣ (១២,៣) | ១១២,៧ (២១,១) | ៨៧,២ (៥៨,០) |
| វិស័យទេសចរណ៍ | ០,០ | ៧៥,២ | ០,០ |
| វិស័យហេដ្ឋារចនាសម្ព័ន្ធនិងផ្សេងៗ | ៩៩,០ | ០,០ | ០,០ |
| ចំនួនគម្រោង ថ្មីនិងពង្រីក (ចំនួន) | ១៧,០ | ២៥,០ | ១០,០ |
| បង្កើតការងារ (ពាន់នាក់) | ២២,៦ | ២៦,៧ | ១៣,៧ |

## ➢សេវាកម្ម

តារាង៤.៥.ការចុះបញ្ជីនិងលុបចេញពីបញ្ជី នៅក្រសួងពាណិជ្ជកម្ម

| ប្រភេទ | ចំនួន–មេសា២០១៨ | ចំនួន–មីនា២០១៨ | ចំនួន–មេសា២០១៧ |
|---|---|---|---|
| ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម | ៩៤១ | ៨៦៧ | ៣៧៣ |
| ក្រុមហ៊ុនត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម | ១៤ | ៩ | ៥ |
| ក្រុមហ៊ុនដែលបានចុះបញ្ជីបង់ពន្ធដារតាមរបបពិត | ៣៤៣ | | ៣៧២ |

➢**ទំនិញឆ្លងកាត់កំពង់ផែ**(សរុប៥កំពង់ផែ) មានចំនួន១០៣២,៦ពាន់តោនកើនឡើង១១% ធៀបនឹងខែមុន និងកើនឡើង៦%ធៀបនឹងខែដូចគ្នាឆ្នាំមុនក្នុងនោះៈ

តារាង៤.៦.ទំនិញឆ្លងកាត់កំពង់ផែផ្សេងៗ (ក្នុងវង់ក្រចកៈ បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន)

| | | | |
|---|---|---|---|
| ▪ កំពង់ផែភ្នំពេញៈ+០,១% | (+៤%) | ▪ កំពង់ផែស្រែអំបិល និងកោះកុងៈ-៣៩% | (+១១២%) |
| ▪ កំពង់ផែកំពង់សោមៈ+៨% | (-០,៥%) | ▪ កំពង់ផែឧកញ៉ាម៉ុងៈ +១០០% | (+៥២%) |

## ➢ប្រៃសណីយ៍និងទូរគមនាគមន៍

| ប្រភេទ | ចំនួន | %∆ ធៀបនឹងខែមុន | %∆ធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|
| បញ្ញើក្នុងប្រទេស(ពាន់កញ្ចប់) | ១៧,១ | -១១% | ១៦% |
| ក្នុងនោះទទួល | ២,២ | -១៣% | ១១% |
| បញ្ញើក្រៅប្រទេស(ពាន់កញ្ចប់) | ៩១,៣ | -២១% | -០,២% |

| ប្រភេទ | ចំនួន | %Δ ធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|
| ក្នុងនោះទទួល | ៤៩,៥ | -៣% | ៧% |
| សន្ទនាទូរសព្ទក្នុងប្រទេស(ពាន់នាទី) | ១៧១១,៤ | -១៦% | -២៤% |
| ក្នុងនោះហៅចូល | ៥៣០,៥ | -១៣% | -២២% |
| សន្ទនាទូរសព្ទក្រៅប្រទេស(ពាន់នាទី) | ៦៧១១,៥ | -១២% | -២២% |
| ក្នុងនោះហៅចូល | ៦៦៤២,៣ | -១២% | -២២% |

➢**ការធ្វើដំណើរតាមផ្លូវអាកាសនិងទេសចរណ៍**

តារាង៤.៧.អ្នកដំណើរតាមផ្លូវអាកាសនិងទេសចរណ៍

| ប្រភេទ | ចំនួន(ពាន់នាក់) | %Δ ធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|
| ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ | ១៦,០ | -៣១% | -១១% |
| អ្នកដំណើរតាមផ្លូវអាកាស (ក្នុងស្រុក) | ៤៥,៩ | -២៧% | ០,០១% |
| អ្នកដំណើរតាមផ្លូវអាកាស (អន្តរជាតិ) | ៧០៩,៨ | -១៧% | ២៣% |
| ចំនួនទេសចរជាតិចេញក្រៅប្រទេស | ២១២,៧ | ៤១,២% | ២០% |
| ចំនួនទេសចរអន្តរជាតិមកព្រះរាជាណាចក្រកម្ពុជា | ៤៦៣,៤ | -១៩% | ១២% |
| ✓ តាមផ្លូវអាកាស | ២៩៧,៦ | -២៥% | ២២% |
| ✓ តាមផ្លូវគោក និងទឹក | ១៦៥,៩ | -៦% | -២% |

## ៥) ស្ថានភាពជញ្ជូនពាណិជ្ជកម្ម

➡ពីប្រភពអគ្គនាយកដ្ឋានគយនិងរដ្ឋាករ ការនាំចូលនាខែមេសា ឆ្នាំ២០១៨ មានចំនួន ៤៧៥៧ប៊ីលានរៀល (ស្មើនឹង១១៨៩,២លានដុល្លារ ស.រ.អា.)កើនឡើង២,៤%ធៀបនឹងខែមុននិងកើនឡើង៧,២%ធៀបនឹងខែដូចគ្នាឆ្នាំមុន ក្នុងនោះ:

តារាង៥.១.បម្រែបម្រួលនៃការនាំចូលមុខទំនិញមួយចំនួន

| ទំនិញ | %Δធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន | ទំនិញ | %Δ□ធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| ប្រេងសាំង | +៦,២% | +៧,៥% | រថយន្តសរុប (ប៊ី.ល.រ) | -១៦,៨% | +១០,៤% |
| ប្រេងម៉ាស៊ូត | +១,០% | +១,៣% | រថយន្តសរុប (គ្រឿង) | -១៥,២% | +៧,៨% |
| ឧស្ម័ន | -១៥,៥% | -២២,៤% | ត្រាក់ទ័រនិងគោយន្ត(គ្រឿង) | -២២,៤% | +០,៥% |
| អគ្គិសនីនាំចូល | -១៧,០% | +៦៩% | ម៉ូតូ (គ្រឿង) | -៣៦,៨% | +៣,០% |
| ដែកសំណង់ | +១២,៦% | +៥០,៧% | អង្ករ | +២៨៦,៨% | +៣៥,៥% |
| ស៊ីម៉ង់ត៍ | -៤៣,១% | +១០,០% | ផ្លែឈើនិងបន្លែ | -៩,២% | +៤,៨% |
| គ្រឿងអេឡិចត្រូនិក | -៣០% | +២០៩,៤% | ជីនិងថ្នាំកសិកម្ម | +៦,៣% | -៧,៣% |
| | | | នាំចូលក្នុងក្របខណ្ឌច្បាប់វិនិ | +៤២,១% | +១២,៨% |

➡ **ការនាំចេញ** ខែមេសាឆ្នាំ២០១៨ មានចំនួន**២៩៧១,២**ប៊ីលានរៀល ស្មើនឹង**៧៤១,៨**លានដុល្លារ ស.រ.អា. (**៦២**% នៃការនាំចូល)ថយចុះ២៧,៨%ធៀបនឹងខែមុន និងថយចុះ៧%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង៥.២.បម្រែបម្រួលនៃការនាំចេញមុខទំនិញមួយចំនួន

| ទំនិញ | %ធៀបនឹងខែមុន | %ធៀបនឹងខែដូចគ្នាឆ្នាំមុន | ទំនិញ | %ធៀបនឹងខែមុន | %ធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| ផលិតផលឈើកែច្នៃ | -៥០,២% | -៥៩,៥% | ផលិតផលនេសាទ | -២៩,០% | +៨៧,៨% |
| វាយនភណ្ឌនិងស្បែកជើង | -៣១,៦% | +១១,៥% | កៅស៊ូ | -៣០,៧% | +៨,៧% |
| អង្ករ | -២៦,៧% | +៨,៣% | | | |

## ៦) បម្រែបម្រួលគួរឲ្យចាប់អារម្មណ៍

ក្នុងខែមេសា ឆ្នាំ២០១៨នេះ សូចនាករសេដ្ឋកិច្ច សង្គមកិច្ច នៃព្រះរាជាណាចក្រកម្ពុជាបង្ហាញបម្រែបម្រួលគួរឲ្យចាប់អារម្មណ៍ដូចក្នុងតារាងខាងក្រោម។

តារាង៦.១. បម្រែមប្រួលគួរឲ្យចាប់អារម្មណ៍ នៃសូចនាករមួយចំនួន

| ល.រ | សូចនាករ | ធៀបនឹងខែមុន | ធៀបនឹងខែដូចគ្នាឆ្នាំមុន | កំណត់សម្គាល់ |
|---|---|---|---|---|
| ១ | ការនាំចេញ | -២៧,៨% | -៧,០% | |
| ២ | ការនាំចេញផលិតផលឈើកែច្នៃ | -៥០,២% | -៥៩,៥% | |

## ៧) សេចក្តីសន្និដ្ឋាន

១) ក្នុងរយៈពេលកន្លងទៅនេះ ថ្លៃប្រេងឥន្ទនៈនៅលើទីផ្សារអន្តរជាតិបានកើនឡើងជាបន្តបន្ទាប់ ជាហេតុនាំអោយថ្លៃប្រេងឥន្ទនៈនៅកម្ពុជាកើនឡើងគួរឲ្យកត់សំគាល់ ហើយការកើនឡើងនេះហាក់ដូចជាលឿនជាងការចុះថ្លៃ។ដូច្នោះគួរតែពិនិត្យឡើងវិញអំពីការកំណត់ថ្លៃគួរតែធ្វើឲ្យបានញឹកញាប់ជាងមុនដើម្បីឲ្យទាន់សភាពការណ៍ឡើងចុះនៅទីផ្សារអន្តរជាតិ។ការឡើងថ្លៃប្រេងឥន្ទនៈបង្កឲ្យមានផលប៉ះពាល់លើគ្រប់វិស័យនៃសេដ្ឋកិច្ច និងជីវភាពរស់នៅរបស់ប្រជាជន។ នៅខណៈពេលដែលប្រេងឥន្ទនៈកំពុងឡើងថ្លៃខ្លាំងគួរតែមានការចូលរួមសហការពីវិស័យឯកជនដែលពាក់ព័ន្ធនឹងប្រេងឥន្ទនៈ ដើម្បីរួមចំណែកធ្វើឲ្យប្រេងឥន្ទនៈកុំឡើងថ្លៃពេក។

២) ដោយសារការអនុវត្ត និងអាកប្បកិរិយាមិនល្អរបស់គ្រូពេទ្យមួយចំនួនបាននាំឲ្យសេវាសុខាភិបាលនៅកម្ពុជាទទួលរងការរិះគន់ពីសាធារណៈជន ដែលតម្រូវឲ្យមានកំណែរទម្រង់ និងគំនិតផ្តួចផ្តើមយុទ្ធសាស្ត្ររយៈពេលវែង ដើម្បីឲ្យវិស័យនេះបានរួមចំណែកសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចផង និងមានលទ្ធភាពប្រកួតប្រជែងលើទីផ្សារក្នុងតំបន់ផង ព្រោះថាសុខាភិបាលជាទីផ្សារសេវាកម្មដ៏ធំមួយដែលមានរូបិយវត្ថុវិលក្នុងវិស័យនេះយ៉ាងច្រើនសន្ធឹកសន្ធាប់ដូចវិស័យទេសចរណ៍ដែរ។ យុទ្ធសាស្ត្រនៃវិស័យសុខាភិបាលគួរមានការផ្តោតលើ កត្តាគន្លឹះមួយចំនួនដូចជាការពង្រឹងក្រមសីលធម៌វិជ្ជាជីវៈ គុណវុឌ្ឍន៍នៃធនធានមនុស្ស ហេដ្ឋារចនាសម្ព័ន្ធរូបវន្តនិងអរូបវន្ត បរិក្ខារ ក្នុងការលើកកំពស់គុណភាពនៃការផ្តល់សេវាដើម្បីប្រកួតប្រជែង៕

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០២/០៥/១៨<br>**ម៉ោង១៤:៣០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីបិទសន្និបាតបូកសរុបការងារកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ២០១៧-២០១៨ និងទិសដៅការងារឆ្នាំ២០១៨-២០១៩ និងសម្ពោធដាក់ឲ្យប្រើប្រាស់អគារថ្មី នៃក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅទីស្តីការក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ។ |
| ២ | ០៥/០៥/១៨<br>**ម៉ោង១៧:៣០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីសំណេះសំណាលជាមួយថ្នាក់ដឹកនាំគ្រីស្ទបរិស័ទ ដើម្បីសុខដុមនីយកម្មគ្រីស្ទសាសនានៅកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ។ |
| ៣ | ០៦/០៥/១៨<br>**ម៉ោង០៧:០០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីអបអរសាទរខួបទី១៥៥ ទិវាពិភពលោកកាកបាទក្រហម អឌ្ឍចន្ទក្រហម ៨ ឧសភា ២០១៨ ក្រោមប្រធានបទ "កាកបាទក្រហមកម្ពុជាមានគ្រប់ទីកន្លែង សម្រាប់គ្រប់ៗគ្នា-មិនទុកនរណាម្នាក់ចោល" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានខេត្តតាកែវ និងលោកជំទាវ នៅសាលមហោស្រពខេត្តតាកែវ។ |
| ៤ | ០៧/០៥/១៨<br>**ម៉ោង០៧:៣០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីបើកការដ្ឋានពង្រីក និងលើកកម្រិតផ្លូវជាតិលេខ៣ ប្រវែង ១៣៤,៨២៦ គ.ម ចាប់ពីភ្នំពេញ(ចោមចៅ)-បែកគូស-ក្រុងកំពត ក្រោមហិរញ្ញប្បទានសម្បទាន ពីរដ្ឋាភិបាល នៃសាធារណរដ្ឋប្រជាមានិតចិន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅភូមិព្រៃកី សង្កាត់ភ្លើងឆេះរទេះ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។ |

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
| --- | --- | --- |
| ៥ | ០៩/០៥/១៨<br>**ម៉ោង០៩:៣០នាទី** | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី។<br>២-សេចក្តីព្រាងច្បាប់ស្តីពីសញ្ជាតិ។<br>៣-សេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មមាត្រា៣ មាត្រា២៣ មាត្រា៣០ មាត្រា៣៣ មាត្រា៣៤ មាត្រា៣៥ មាត្រា៣៦ មាត្រា៣៧ មាត្រា៣៨ មាត្រា៣៩ និងមាត្រា៤០ នៃច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ ដែលត្រូវប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០១/០៩ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០១។<br>៤-បញ្ហាផ្សេងៗ។<br>ដើម្បីត្រៀមប្រជុំត្រួតពិនិត្យចុងក្រោយជាមួយ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជារដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៦ | ១១/០៥/១៨<br>**ម៉ោង០៨:៣០នាទី** | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១-សេចក្តីព្រាងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី។<br>២-សេចក្តីព្រាងច្បាប់ស្តីពីសញ្ជាតិ។<br>៣-សេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មមាត្រា៣ មាត្រា២៣ មាត្រា៣០ មាត្រា៣៣ មាត្រា៣៤ មាត្រា ៣៥ មាត្រា៣៦ មាត្រា៣៧ មាត្រា៣៨ មាត្រា៣៩ និងមាត្រា៤០ នៃច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ ដែលត្រូវប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០១/០៩ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០១។<br>៤-បញ្ហាផ្សេងៗ៖សំណើសុំការយល់ព្រមពីគណៈរដ្ឋមន្ត្រី ដើម្បីសុំសច្ចាប័ននីតិប្បញ្ញត្តិលើកិច្ចព្រមព្រៀង ស្តីពីការបង្កើតអង្គការសហប្រតិបត្តិការព្រៃឈើអាស៊ី (AFoCO)។<br>នៅទីស្តីការនាយករដ្ឋមន្ត្រី។ |

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ៧ | **១១/០៥/១៨ ម៉ោង១៦:០០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីចុះហត្ថលេខារវាងវេទិកាសម្ព័ន្ធសង្គមស៊ីវិល (វ.ស.ស) ជាមួយ CFPD និង វេទិកាសម្ព័ន្ធសង្គមស៊ីវិល (វ.ស.ស) ជាមួយ SFIEC ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជារដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៨ | **១៤/០៥/១៨ ម៉ោង០៧:០០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការ អគារមិត្តភាពកម្ពុជា-កូរ៉េ នៃមន្ទីរពេទ្យកុមារជាតិ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅមន្ទីរពេទ្យកុមារជាតិ សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ។ |
| ៩ | **១៦/០៥/១៨ ម៉ោង០៨:៣០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីបើកសន្និបាតជាតិបូកសរុបសមិទ្ធផលវិស័យសកម្មភាពមីនរយៈពេល២៥ឆ្នាំ និងផ្សព្វផ្សាយផែនការយុទ្ធសាស្រ្តជាតិសកម្មភាពមីន២០១៨-២០២៥ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជារដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ១០ | **១៧/០៥/១៨ ម៉ោង១៥:០០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីបិទសន្និបាតជាតិបូកសរុបសមិទ្ធផលវិស័យសកម្មភាពមីនរយៈពេល២៥ឆ្នាំ និងផ្សព្វផ្សាយផែនការយុទ្ធសាស្រ្តជាតិសកម្មភាពមីន២០១៨-២០២៥ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ១១ | **១៩/០៥/១៨ ម៉ោង០៨:៣០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីសំណេះសំណាល និងបំពាក់មេដាយការពារជាតិជូនអតីតយុទ្ធជនកម្ពុជាខេត្តតាកែវ ចំនួន ១ ០០០នាក់ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជារដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅបរិវេណលេខាធិការដ្ឋានក្រុមប្រឹក្សាខេត្តតាកែវ។ |
| ១២ | **២០/០៥/១៨ ម៉ោង០៨:០០នាទី** | ចូលរួមជាសហាធិបតី ក្នុងកម្មវិធីទិវាជាតិនៃការចងចាំ ២០ ឧសភា ២០១៨ នៅភូមិថ្នល់បត់ ឃុំបានកាម ស្រុកព្រៃកប្បាស ខេត្តតាកែវ។ |

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
| --- | --- | --- |
| ១៣ | **២២/០៥/១៨ ម៉ោង០៧:០០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីប្រគល់សញ្ញាបត្រថ្នាក់បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជូនដល់និស្សិត នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ។ |
| ១៤ | **២២/០៥/១៨ ម៉ោង១៥:០០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីផ្តល់ប្រាក់រង្វាន់ជូនជ័យលាភីក្នុងការចូលរួមប្រកួតកីឡាតេក្វាន់ដូ ITF ជ្រើសរើសជើងឯកអាស៊ីលើកទី៩ នៅប្រទេសម៉ុងហ្គោលី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ១៥ | **២៣/០៥/១៨ ម៉ោង០៩:៣០នាទី** | ដឹកនាំកិច្ចប្រជុំក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានឃុំព្រៃកប្បាស ស្រុកព្រៃកប្បាស ខេត្តតាកែវ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៦ | **២៣/០៥/១៨ ម៉ោង១០:៣០នាទី** | ដឹកនាំកិច្ចប្រជុំក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានឃុំ០៦ នៃស្រុកព្រៃកប្បាស ខេត្តតាកែវ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៧ | **២៤/០៥/១៨ ម៉ោង០៩:៣០នាទី** | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើៈ<br>១-សេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មមាត្រា៨៧ ចំណងជើងចំណុច”គ” នៃផ្នែកទី៣ ជំពូកទី៤ មាត្រា៨៩ មាត្រា៩០ មាត្រា៩១ មាត្រា៩៤ មាត្រា១១០ មាត្រា១២០ និងមាត្រា១២២ នៃច្បាប់ស្តីពីការងារដែលត្រូវប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧។<br>២-សេចក្តីព្រាងច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមា។<br>៣-សេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មមាត្រា៣ មាត្រា៦ មាត្រា៧ មាត្រា៨ មាត្រា៩ មាត្រា១១ មាត្រា១២ ចំណងជើងជំពូកទី៤ មាត្រា១៦ មាត្រា១៩ មាត្រា២៦ មាត្រា៥០ មាត្រា៥១ មាត្រា៥២ មាត្រា៥៣ មាត្រា៥៤ មាត្រា៥៥ មាត្រា៥៦ មាត្រា៥៧ មាត្រា៥៨ មាត្រា៥៩ មាត្រា៦៥ មាត្រា៦៦ មាត្រា៦៧ និងមាត្រា៦៨ នៃច្បាប់ស្តីពីស្តង់ដាកម្ពុជា ដែលត្រូវប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៣ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៧។ |

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| | | ៤-គម្រោងវិនិយោគសាងសង់រោងចក្រផលិតអគ្គិសនីដុតធ្យូងថ្មអានុភាព ៧០០មេហ្កាវ៉ាត់ នៅខេត្តព្រះសីហនុ និងគម្រោងវិនិយោគសាងសង់រោងចក្រផលិតអគ្គិសនីដើរដោយពន្លឺព្រះអាទិត្យអានុភាព ៦០មេហ្កាវ៉ាត់ នៅខេត្តកំពង់ស្ពឺ។<br>៥-បញ្ហាផ្សេងៗ។<br>ដើម្បីត្រៀមប្រជុំត្រួតពិនិត្យចុងក្រោយជាមួយ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជារដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៨ | **២៤/០៥/១៨ ម៉ោង១៥:០០នាទី** | ចូលរួមជាសមាជិកក្នុងកិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ សម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជារដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មមាត្រា៨៧ ចំណងជើងចំណុច"គ" នៃផ្នែកទី៣ ជំពូកទី៤ មាត្រា៨៩ មាត្រា៩០ មាត្រា៩១ មាត្រា៩៤ មាត្រា១១០ មាត្រា១២០ និងមាត្រា១២២ នៃច្បាប់ស្តីពីការងារដែលត្រូវប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧។<br>២-សេចក្តីព្រាងច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមា។<br>៣-សេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មមាត្រា៣ មាត្រា៦ មាត្រា៧ មាត្រា៨ មាត្រា៩ មាត្រា១១ មាត្រា១២ ចំណងជើងជំពូកទី៤ មាត្រា១៦ មាត្រា១៩ មាត្រា២៦ មាត្រា៥០ មាត្រា៥១ មាត្រា៥២ មាត្រា៥៣ មាត្រា៥៤ មាត្រា៥៥ មាត្រា៥៦ មាត្រា៥៧ មាត្រា៥៨ មាត្រា៥៩ មាត្រា៦៥ មាត្រា៦៦ មាត្រា៦៧ និងមាត្រា៦៨ នៃច្បាប់ស្តីពីស្តង់ដាកម្ពុជា ដែលត្រូវប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៣ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៧។<br>៤-គម្រោងវិនិយោគសាងសង់រោងចក្រផលិតអគ្គិសនីដុតធ្យូងថ្មអានុភាព ៧០០មេហ្កាវ៉ាត់ នៅខេត្តព្រះសីហនុ និងគម្រោងវិនិយោគសាងសង់រោងចក្រផលិតអគ្គិសនីដើរដោយពន្លឺព្រះអាទិត្យអានុភាព ៦០មេហ្កាវ៉ាត់ នៅខេត្តកំពង់ស្ពឺ។<br>៥-បញ្ហាផ្សេងៗ។ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១៩ | **២៥/០៥/១៨ ម៉ោង០៨:៣០នាទី** | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១-សេចក្ដីព្រាងច្បាប់ស្ដីពីវិសោធនកម្មមាត្រា៨៧ ចំណងជើងចំណុច"គ" នៃផ្នែកទី៣ ជំពូកទី៤ មាត្រា៨៩ មាត្រា៩០ មាត្រា៩១ មាត្រា៩៤ មាត្រា១១០ មាត្រា១២០ និងមាត្រា១២២ នៃច្បាប់ស្ដីពីការងារដែលត្រូវប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧។<br>២-សេចក្ដីព្រាងច្បាប់ស្ដីពីប្រាក់ឈ្នួលអប្បបរមា។<br>៣-សេចក្ដីព្រាងច្បាប់ស្ដីពីវិសោធនកម្មមាត្រា៣ មាត្រា៦ មាត្រា៧ មាត្រា៨ មាត្រា៩ មាត្រា១១ មាត្រា១២ ចំណងជើងជំពូកទី៤ មាត្រា១៦ មាត្រា១៩ មាត្រា២៦ មាត្រា៥០ មាត្រា៥១ មាត្រា៥២ មាត្រា៥៣ មាត្រា៥៤ មាត្រា៥៥ មាត្រា៥៦ មាត្រា៥៧ មាត្រា៥៨ មាត្រា៥៩ មាត្រា៦៥ មាត្រា៦៦ មាត្រា៦៧ និងមាត្រា៦៨ នៃច្បាប់ស្ដីពីស្ដង់ដាកម្ពុជា ដែលត្រូវប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៣ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៧។<br>៤-គម្រោងវិនិយោគសាងសង់រោងចក្រផលិតអគ្គិសនីដុតធ្យូងថ្មអានុភាព ៧០០មេហ្គាវ៉ាត់ នៅខេត្តព្រះសីហនុ និងគម្រោងវិនិយោគសាងសង់រោងចក្រផលិតអគ្គិសនីដើរដោយពន្លឺព្រះអាទិត្យអានុភាព ៦០មេហ្គាវ៉ាត់ នៅខេត្តកំពង់ស្ពឺ។<br>៥-បញ្ហាផ្សេងៗ។ នៅទីស្ដីការនាយករដ្ឋមន្ត្រី។ |
| ២០ | **២៥/០៥/១៨ ម៉ោង១៦:០០នាទី** | ចូលរួមជាកិត្តិយសក្នុងពិធីបើកការប្រកួតកីឡាជាតិលើកទី២ ក្រោមប្រធានបទ "កីឡា ដើម្បីសន្តិភាព និងការអភិវឌ្ឍ" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត** នៅពហុកីឡដ្ឋានជាតិ (អូឡាំពិក)។ |
| ២១ | **២៩/០៥/១៨ ម៉ោង១៦:៣០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីពិសារអាហារស្រាយបួស ខែរ៉ាម៉ាឌន ឆ្នាំ២០១៨ នៃសាសនាឥស្លាមកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង **សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត** នៅមជ្ឈមណ្ឌលពិព័រណ៍កោះពេជ្រ។ |
| ២២ | **៣១/០៥/១៨ ម៉ោង០៩:៣០នាទី** | ដឹកនាំកិច្ចប្រជុំគណៈកម្មការត្រួតពិនិត្យនិងវាយតម្លៃស្ថានភាពហិរញ្ញវត្ថុ និងទុនវិនិយោគរបស់ក្រុមហ៊ុនសម្បទានព្រលានយន្តហោះ (SCA) នៅទីស្ដីការគណៈរដ្ឋមន្ត្រី។ |
| ២៣ | **៣១/០៥/១៨ ម៉ោង១៥:៣០នាទី** | ដឹកនាំកិច្ចប្រជុំគណៈកម្មការតាមដាន និងត្រួតពិនិត្យលើការសាងសង់អាកាសយានដ្ឋានអន្តរជាតិ ប្រចាំខែមេសា ឆ្នាំ២០១៨ នៅទីស្ដីការគណៈរដ្ឋមន្ត្រី។ |

# ព្រឹត្តិបត្រព័ត៌មាន



## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌


ទូរស័ព្ទលេខ: ០២៣ ២១១ ៩៤៣ ០១៦ ៣០៧ ៣៣០

ទូរសារលេខ: ០២៣ ២១១ ៩៤៣

E-mail: veasna@live.in